# រឿងព្រះមហោសថ



Tome III
Roeung Preah Mahosoth
INDOCHINE FRA[NÇAISE]
RÉGIE DU DÉPÔT LÉGAL
B-3
D-24
N-2929

ARCHIVES NATIONALES
REGIE DU DEPOT LEGAL



ARCHIVES NATIONALES
COTE B. 61-594
24

កាលណោះព្រះពោធិសត្វបង់ល្បងនាងទៀត ក៏ប្រាប់ថាៈ ម្នាលនាង ឥឡូវនេះ បងនឹងផ្ញើនាងទុកនៅផ្ទះនាយឆ្មាំទ្វារនេះសិនបងនឹងចូលទៅមុន ៗ លុះព្រះអង្គទៅដល់លំនៅអាត្មាហើយ ក៏ប្រាប់ទៅបុរសម្នាក់ថាៈ អញផ្ញើទុកស្រីម្នាក់នៅផ្ទះនាយឆ្មាំទ្វារឯណោះ ចូរព្រះស្តែងយកមាស ១០០០ ដម្លឹង ទៅឲ្យស្រីនោះលងមើល ៗ បុរសនោះក៏ធ្វើតាមបង្គាប់ លុះដល់ហើយ ក៏និយាយថាៈ ម្នាលនាងចូរនាងទៅនៅនឹងបង ៗ ឲ្យមាស ១០០០ ដម្លឹង នាងប្រាប់មកវិញថាៈ មាស ១០០០ ដម្លឹងនេះ មិនស្មើនឹងលម្អងធូលីជើងប្តីខ្ញុំផង ៗ បុរសនោះក៏មកប្រាប់ព្រះមហោសថវិញ ព្រះអង្គក៏ប្រើបុរសដដែល ទៅល្បងជាគំរប់ពីរ-បី ដង ក៏នាងនៅតែជាដូច្នោះទៀត ទើបព្រះអង្គប្រើបុរសឲ្យទៅនាំនាងចូលមក, នាងអមរាមកដល់ឃើញព្រះពោធិសត្វ មានសម្បត្តិនឹងបរិវារច្រើនដូច្នោះ នាងស្មានថាជាព្រះមហាក្សត្រ ទើបនាងសើចហើយយំវិញ ព្រះពោធិសត្វក៏សួរហេតុនោះនាងជំរាបថាៈ បពិត្រព្រះកស្តា ខ្ញុំឃើញសម្បត្តិច្រើន ហេតុតែអំពើកុសលដែលព្រះកស្តាបានកសាងអំពីបុព្វជាតិ ហេតុនេះបានជាខ្ញុំសើច ឯខ្ញុំយំវិញនោះ គឺនឹកឃើញថា ព្រះកស្តា ដណ្តើមរបស់អ្នកដទៃ ដែលគេរក្សាព្យាបាលដូច្នេះ មុខជានឹងសោយទុក្ខវេទនាក្នុងនរកនាយ ៗ

ព្រះពោធិសត្វល្បងនាងដឹងថា ជាស្រីសុភាពបរិសុទ្ធ ហើយក៏ប្រើឲ្យបុរសម្នាក់នាំនាងទៅទុកកន្លែងដដែលវិញ ៗ លុះព្រឹកឡើង

ព្រះពោធិសត្វ ចូលទៅប្រាប់ដល់នាងឧទុម្ពរទេវី ជាព្រះអគ្គមហេសីនៃព្រះបាទវិទេហរាជ ; នាងឧទុម្ពរទេវីក៏ទូលរឿងនោះដល់ព្រះរាជា ។ ទ្រង់ជ្រាបហើយ ក៏ឲ្យប្រដាប់គ្រឿងតាំងតួន ដើម្បីទៅទទួលព្រះពោធិ-សត្វនិងនាងអមរា ឲ្យឡើងជិះលើរាជរថដ៏ប្រសើរ នាំមកកាន់ផ្ទះព្រះមហោសថ ។ លុះមកដល់ហើយ ព្រះអង្គទ្រង់ព្រះរាជទានមាស ១០០០



ដម្ហឹង ទឹងអ្នកផ្ដាំទ្វារព្រមទាំងកែវកងជាច្រើនមកពោធិសត្វទឹងនាងអមរា ។ ក៏ទទួលយកគ្រឿងបណ្ណាការនោះ ។ នាងអមរាបានទ្រព្យសម្បត្តិច្រើនដូច្នោះហើយ នាងបែងទ្រព្យជាពីរភាគគឺ ១ ភាគសម្រាប់ចែកដល់ព-ពួកមហាជន , ១ ភាគទៀតសម្រាប់ដាក់ឃ្លាំងជាព្រះរាជទ្រព្យ ។ ហេតុនេះហើយបានជាពពួកមហាជនចោមរោមស្រឡាញ់រាប់អានគោរពកោតខ្លាច ទទួលស្ដាប់ដំបូន្មានអស់ទាំងនគរ ។ ចំណែកខាងអាចារ្យទាំង ៤ នាក់ ក៏សាបសូន្យដូចជាពន្លឺអំពិលអំពែកក្នុងពេលវេលាថ្ងៃ ម្ល៉ោះហើយចេះតែរិះរកទោសព្រះមហោសថពល់វេលា លុះមិនឃើញទោសអ្វីបន្តិចបន្តួចសោះ ក៏កាន់តែមានចិត្តប្រទុស្ត ក្ដៅឡើង ៗ ។

មានកាលសម័យថ្ងៃមួយ អាចារ្យទាំង ៤ និយាយគ្នាថា: យើងនេះមានអំណាចប្រាជ្ញាមិនស្មើព្រះមហោសថឡើយ ឥឡូវនេះព្រះមហោសថនាំប្រពន្ធមកមានប្រាជ្ញាឆ្លាតវៃដូចគ្នាទៀត បើដូច្នោះ យើងនឹងរកឧបាយកល ចាប់ទោសព្រះមហោសថដូចម្ដេចទៅ? អាចារ្យសេនកៈឆ្លើយថា: ការណ៍នេះមិនជាអ្វីទេ បើដូច្នោះ យើងនឹងបបួលគ្នាទៅលួចយកកែវមណីរ័តន៍ទាំង ៤ មុខរបស់ព្រះរាជា ។ លុះលួចបានហើយក៏យកៈទៅផ្ទះពល់ៗខ្លួនៗ អាចារ្យសេនកៈយកកែវមណីរ័តន៍មួយដាក់ក្នុងទឹកក្អមប្រគល់ឲ្យខ្ញុំស្រីយកទៅលក់ហើយផ្ដាំថា: បើអ្នកដទៃៗទិញ នាងឯងកុំលក់ បើមនុស្សក្នុងផ្ទះមហោសថសុំ នាងឯងលក់ ។ នាងនោះក៏ទូលទឹកក្អមទៅដល់ផ្ទះមហោសថហើយនិយាយថា: ហៃអ្នកម្ចាស់ផ្ទះចូរអ្នកទិញទឹក

ក្អមនេះទុកពីសារទៅ ៗ កាលនោះនាងអមរា អង្គុយនៅមាត់ទ្វារផ្ទះ នាងយល់អំពើស្រីនោះពុំដើរទៅឯណា នាងគិតថា: អំពើនេះសមរបើ មានប្រស្នាមិនខានឡើយ ហើយនាងក៏ប្រើខ្ញុំស្រីឲ្យទៅប្រាប់ឲ្យចេញ ទៅលក់ឯទៀតទៅ ៗ មីស្រីនោះវាក៏នៅតែមិនដើរទៅ នាងអមរាឃើញ ដូច្នោះ នាងឲ្យហៅមកកាន់ផ្ទះហើយសួរថា: ឱ នាងក្រមុំព្រហ្មចារី នាង ឈ្មោះអ្វី? ស្រីនោះប្រាប់ថា: ខ្ញុំនេះជាទាសីអាចារ្យសេនកៈ គាត់ប្រើឲ្យ មកលក់ទឹកក្អមនេះ នាងអមរាសួរហេតុសព្វគ្រប់នាងធ្វើជាសំបុត្រកត់ បំណាំថា “ពីថ្ងៃព្រហស្បតិ៍ ១៥ កើតខែពិ.ហ១ អាចារ្យសេនកៈបាន ប្រើខ្ញុំស្រី ឲ្យយកគ្រឿងប្រដាប់មកដល់ផ្ទះមហោសថអ្នកប្រាជ្ញ នាង ក៏យកទុក ហើយឲ្យខ្ញុំស្រីនោះទៅកាន់ផ្ទះអាចារ្យសេនកៈវិញទៅ ៗ

អាចារ្យបុក្កុសៈ យកសុវណ្ណមាលាមាសដាក់ក្នុងប្រអប់ផ្កាកៀ អាចារ្យកាមិន្ទៈ យកសំពត់កម្ពលទុកក្នុងកញ្ចើ ហើយយកបន្លែដាក់ ខាងលើ អាចារ្យទេវិន្ទៈ យកសុវណ្ណបាទុកា បង់ទុកក្នុងកណ្ដាប់ស្រូវ អាចារ្យទាំង ៣ នេះ ក៏ប្រើខ្ញុំស្រី ឲ្យយកទៅដល់ផ្ទះមហោសថដែរ ៗ នាងអមរា ក៏កត់ហេតុទាំងអស់គ្មានសល់ នាងទទួលទុកហើយនាងប្រាប់ ដល់មហោសថជាកស្ដា ៗ

ឯកស្មឹ សមយេ ក្នុងសម័យមួយ អាចារ្យទាំង ៤ នោះឡើងទៅ គាល់ព្រះបាទវិទេហរាជ ហើយធ្វើជាក្រាបទូលថា: បពិត្រព្រះភូមិន្ទ សព្វថ្ងៃរៀងមក ព្រះអង្គទ្រង់ប្រដាប់គ្រឿងទាំង ៤ យ៉ាង ចុះឥឡូវនេះ

ហេតុអ្វីក៏ព្រះអង្គមិនទ្រង់ប្រដាប់គ្រឿងតាំងនោះ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ស្ដេចក៏ប្រើអាមាត្យទៅយកគ្រឿងប្រដាប់តាំង ៤ មុខនោះ ៗ អាមាត្យទៅរកមិនឃើញ ក៏មកក្រាបទូលវិញ, ព្រះរាជាទ្រង់គ្រាំគ្រាផតិពេជក្រៃលែង ៗ អាចារ្យទាំង ៤ ទូលទៀតថា: បពិត្រព្រះសម្មតិទេពគ្រឿងជ័យមង្គលនោះ ប្រហែលជានៅផ្ទះមហោសថហើយ បើដូច្នោះ សូមព្រះអង្គប្រើរាជអាមាត្យឲ្យទៅសួរ បើមហោសថនោះជាសត្រូវទ្រុស្ដមិត្រលួចគ្រឿងជ័យមង្គលនេះ សូមព្រះអង្គឲ្យរាជអាមាត្យទៅដោយបេមចាប់មហោសថ មកធ្វើទុកទោសកុំខាន ៗ

ពួកមនុស្សខ្មាំងមហាជនឮពាក្យអាចារ្យទាំង ៤ នាក់ក្រាបទូលស្ដេចដូច្នោះហើយ ក៏បបួលគ្នាទៅប្រាប់ដល់មហោសថអ្នកប្រាជ្ញ ព្រះអង្គទ្រង់គិតថា: បើអញទៅឲ្យស្ដេចឃើញ មុខជាខាល់ទីនអញមិនខាន បើដូច្នោះគួរតែអញលបរត់ចៀសចេញទៅ ហើយព្រះអង្គក៏ប្រាប់ដល់នាងអមរាជាភរិយាឲ្យប្រាជ្ញដឹង រួចយកសម្ពត់ចាស់មកស្លៀកពុំឲ្យគេស្គាល់ឡើយ ហើយរត់ចេញពីនគរទៅ ៗ

ឯអ្នកនគរទាំងឡាយឮថាព្រះមហោសថរត់បាត់ទៅដូច្នោះ ក៏កើតគោលាហលជ្រួលច្របល់ទៅវិញទៅមកក្រៃពេក ៗ ឯអាចារ្យទាំង ៤ ក៏ទះទ្រូងទះស្មាអរ ហើយគិតគ្នាថា យើងបើតតពីមហោសថនេះទៅហើយ យើងកុំគិតប្រាថ្នាអ្វី យើងយកគ្រឿងបណ្ណាការទៅឲ្យនាងអមរាកុំឲ្យអ្នកណាដឹងឡើយ ហើយយើងទាំងយកជាភរិយាសង្វាសយើង,

អាចារ្យទាំង ៤ នាក់ក៏ធ្វើតាមគំនិតនោះ ៗ ឯនាងអមកទទួលយកគ្រឿងបណ្ណាការទាំងនោះហើយនាងឲ្យទៅប្រាប់ ឲ្យអាចារ្យសេនកៈមកក្នុងវេលាព្រះអាទិត្យអស្តង្គត ៗ ហើយនាងឲ្យខ្ញុំស្រីទាំងឡាយជីករណ្តៅមួយឲ្យដាក់សុទ្ធតែលាមក ហើយគ្របក្តារយន្តពីលើរួចក្រាលកន្ទេលស្អាតបាតទឹងរៀបចំរណ្តាប់ មានទឹកអប់ទឹងផ្កាជាដើម ៗ ឯអាចារ្យសេនកៈលុះដល់ពេលក៏មកដល់ នាងអមកឃើញហើយនិយាយថា: ឱ !! អ្នកឥឡូវនេះខ្ញុំលុះក្នុងអំណាចអ្នកហើយ បរអ្នកទៅងូតទឹកជម្រះក្អែលញើសឲ្យស្អាតៈហើយសឹមមក អាចារ្យសេនកៈក៏ធ្វើតាមពាក្យនាង បំណែកពួកខ្ញុំស្រីនាងអមកយកទឹកស្រោចលើអាចារ្យសេនកៈ ហើយដាន់ក្តារយន្តពេញទំហឹងរបូតអាចារ្យសេនកៈនោះធ្លាក់ទៅក្នុងរណ្តៅលាមកនោះទៅបំ-ណែកអាចារ្យ ៣ នាក់ទៀត នាងផ្តាំឲ្យមកហើយ នាងឲ្យធ្វើដូចមុនក៏ធ្លាក់ទៅក្នុងរណ្តៅលាមកទាំងអស់គ្នា ៗ អាចារ្យទាំង ៤ ធ្លាក់ទៅក្នុងរណ្តៅលាមកជុំគ្នាហើយក៏និយាយគ្នាថា: ឥឡូវនេះយើងធ្វើដូចម្តេច? អាចារ្យបុក្កុសៈថា កុំនិយាយខ្លាំងពេកគាត់! អំពើនេះមុខជាយើងខ្មាស់មហាជនពេលទឹងហើយ អាចារ្យទាំង ៤ នៅក្នុងរណ្តៅលាមកអស់មួយយប់ ប្រឡាក់លាមកពេញខ្លួនទាំងអស់ លុះព្រឹកឡើង នាងបង្គាប់ឲ្យពួកមហាជនយកពួរទៅចងអាចារ្យទាំង ៤ នាក់ អូសឡើងអំពីរណ្តៅលាមកនោះមកហើយឲ្យងូតទឹកឲ្យស្អាត រួចយកឥដ្ឋដុះក្បាលឲ្យចេញឈាម ហើយនាងឲ្យកិនម្សៅ កូរជាបបរឲ្យខាប់ឲ្យលាបតាំងអំពីក្បាលរហូតដល់ជើង

ហើយយកសំលីទៅបិតពេញ ទាំងខ្លួន រួចឲ្យរុំនឹងកន្ទេលចងឲ្យជាប់ហើយ ដាក់ក្នុងទ្រុង នាងឲ្យមហាជននាំគ្នាសែងទៅថ្វាយព្រះរាជា ដល់ហើយ នាងក្រាបទូលថា: បពិត្រព្រះសម្មតិទេព សូមព្រះអង្គទតអាចារ្យទាំង ៤ រុំនៅក្នុងកន្ទេលនេះ ស្ដេចបើកឡើងឃើញអាចារ្យទាំង ៤ ដូចស្វា មហាជនក៏សើចទ្រហឹងអឺងកង: ៗ អាចារ្យទាំង ៤ ក៏ខ្មាស់គេក្នុងពេលនោះ



យ៉ាងក្រៃលែង ហើយនាងក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គ មហោសថខ្ញុំព្រះអង្គ មិនមែនជាចោរទេ ឯចោរនោះគឺអាចារ្យទាំង ៤ នេះពិត អាចារ្យសេនកៈជាចោរលួចយកកែវមណីរតន៍ អាចារ្យបុក្កុសៈ ជាចោរលួចយកសុវណ្ណមាលា អាចារ្យកាមិន្ទៈ ជាចោរលួចយកសំពត់ កម្ពល អាចារ្យទេវិន្ទៈជាចោរលួចយកសុវណ្ណបាទុកា អ្នកទាំង៤នេះប្រើខ្ញុំស្រីយកទៅដល់ផ្ទះ ខ្ញុំព្រះអង្គៗ ទទួលអំពីដៃខ្ញុំស្រីនោះមានឈ្មោះនឹងខែថ្ងៃនៅក្នុងសំបុត្រនេះ សូមព្រះអង្គទ្រង់ទត ហើយសូមទទួលព្រះរាជទ្រព្យនេះវិញ ។ នាងធ្វើអាចារ្យទាំង ៤ ឲ្យលំបាកខ្មាស់គេជាច្រើន ហើយនាងវិលមកកាន់ផ្ទះនាងវិញ ។ ឯព្រះរាជាក៏នៅតែមិននឹកដល់ព្រះមហោសថ ស្ដេចឲ្យអាចារ្យទាំង ៤ នោះង្ងូតទឹក ហើយឲ្យទៅផ្ទះរៀងៗខ្លួន ។

គួរឲ្យអស្ចារ្យ ស្រាប់តែរំជួលដល់ទេពតា ៗ ក៏ហោះមកចោទប្រស្នាបំពោះព្រះរាជាៗ រកមិនឃើញ ឲ្យអាចារ្យទាំង៤រកក៏រកមិនឃើញ ទ្រង់រកបុគ្គលណាមួយដោះស្រាយប្រស្នានោះមិនបាន ទើបទ្រង់ភ័យតក់ស្លុតញាប់ញ័រ ត្រាស់បង្គាប់ឲ្យរត់រកព្រះមហោសថបរមពោធិសត្វ លួងលោមឲ្យព្រះពោធិសត្វវិលត្រឡប់មកវិញ ។ ដល់ព្រះពោធិសត្វយាងមក ក៏ទ្រង់ដោះស្រាយប្រស្នានោះថ្វាយដោយស្រួល ។ ព្រះរាជាក៏មានព្រះទ័យរីករាយសោមនស្ស បំពោះព្រះមហោសថបរមពោធិសត្វយ៉ាងក្រៃលែង ទ្រង់ប្រទានរង្វាន់និងយសស័ក្តិដល់ព្រះពោធិសត្វ ។

ក្នុងសម័យមួយ អាចារ្យទាំង ៤ នាក់គិតគ្នាថាៈ ឥឡូវនេះ ចៅម-

ហោសថ កើតយសស័ក្តិច្រើនលើសយើងទាំងអស់គ្នា បើដូច្នេះយើងនឹងធ្វើដូចម្តេច? អាចារ្យសេនកៈឆ្លើយឡើងថា: យើងនឹងចូលគាល់សំណាក់ព្រះមហោសថធ្វើគួរសម ហើយយើងសួរថាសេចក្តីកំបាំង យើងគួរសំដែងប្រាប់អ្នកណា? បើមហោសថថាមិនគួរប្រាប់អ្នកណាទេ យើងនឹងនាំពាក្យនោះទៅក្រាបទូលព្រះរាជាបង្គាប់ថា: មហោសថនឹងបង្កើតជាសត្រូវចំពោះព្រះអង្គ ស្តេចមុខជានឹងជឿពាក្យយើង ; អាចារ្យទាំងអស់ក៏ព្រមព្រៀងគ្នាដូច្នោះហើយ ក៏ទៅសួរតាមគំនិតដែលគិត, ព្រះមហោសថប្រាប់ថា សេចក្តីកំបាំងយើងមិនគួរប្រាប់ដល់អ្នកដទៃក្រៅអំពីខ្លួនឯងឡើយ, អាចារ្យទាំង ៤ ឮហើយ ក៏មានចិត្តរីករាយដោយត្រូវតាមបំណងរួចទៅទូលព្រះរាជាថា មហោសថគិតនឹងជាសត្រូវទ្រស្តមិត្រចំពោះព្រះអង្គ ៗ ព្រះរាជាទ្រង់ឆ្លើយថាមហោសថមិនគួរក្បត់នឹងអញ មិនគួរជាសត្រូវនឹងអញ អ្នកទាំងឡាយថាមែនឬ? ប្រាកដមែនព្រះអង្គ ! បើព្រះអង្គមិនជឿសូមហៅមហោសថមកសួរថា សេចក្តីកំបាំងគួរសំដែងប្រាប់អ្នកណា បើមហោសថមិនជាសត្រូវមុខជាទូលថា ត្រូវប្រាប់ដល់អ្នកនេះអ្នកនោះ, បើជាសត្រូវនឹងទូលថា មិនត្រូវប្រាប់ដល់អ្នកណាមួយឡើយ ព្រះអង្គនឹងទ្រង់ជ្រាបក្នុងកាលនោះ, ព្រះរាជាក៏ទ្រង់ជឿតាមពាក្យអាចារ្យទាំង ៤ នោះ ៗ

សម័យមួយ ព្រះមហោសថ នឹងអាចារ្យទាំង ៤ ឡើងទៅគាល់ព្រះរាជា ព្រះអង្គមានព្រះរាជឱង្ការថា ម្នាលអ្នកទាំង ៥ ការតិះដៀលក្តី សេចក្តីសរសើរក្តី ការកំបាំងក្តី តើគួរសំដែងប្រាប់ដល់អ្នកណា ?

អាចារ្យសេនកៈឮហើយក៏មានចិត្តត្រេកអរក្រៃលែង ព្រោះត្រូវតាមគំនិត ទើបក្រាបទូលថាៈ មហារាជ បពិត្រមហារាជ ខ្ញុំព្រះអង្គទាំង៤នាក់ពិចារណារៀងៗខ្លួនស្រេចហើយ ប៉ុន្តែសូមព្រះអង្គឆ្លើយប្រស្នានេះជាមុនឲ្យច្បាស់ប្រាកដ ដ្បិតព្រះអង្គជាអធិបតីធំលើយើងទាំងឡាយ សឹមខ្ញុំព្រះអង្គទាំងអស់គ្នាឆ្លើយថ្វាយជាខាងក្រោយ ៗ ព្រះរាជាទ្រង់មានបន្ទូលថា ប្រពន្ធឯណាជាស្ត្រីមានសីលស្រគត់ស្រគំ ឥន្ទ្រីយប្រព្រឹត្តសុចរិត អ្នកដទៃល្បួងប្រព្រឹត្តអាក្រក់ដោយកិលេសមិនបាន គប្បីសម្តែងនូវគោរដំនៀលក្តី ការសរសើរក្តី ការគំបាំងទាំងពួងក្តីដល់ប្រពន្ធនោះ ៗ ស្តេចមានព្រះបន្ទូលដូច្នោះហើយ ទ្រង់សួរទៅអាចារ្យសេនកៈថា បើប្រស្តែងវិញតើនឹងប្រាប់ដល់អ្នកណា ? សូមក្រាបទូលមិត្តឯណាដែលគាប់ចិត្តជាទីពឹងពុំនាក់បាន គួរថ្លែងប្រាប់ដល់មិត្តនោះ ៗ អាចារ្យបុក្កុសៈក្រាបទូលថា បងប្អូនដែលមានឥន្ទ្រិយស្រគត់ស្រគំគួរប្រាប់ដល់បងប្អូននោះ , អាចារ្យកាមិន្ទៈ ក្រាបទូលថា បើកូនមានចិត្តល្អមិនដែលឲ្យមានហ្មងទងឪពុកម្តាយ គួរប្រាប់ដល់កូននោះ , អាចារ្យទេវិន្ទៈ ក្រាបទូលថា បើម្តាយស្រឡាញ់ពេញចិត្តនឹងកូនមិនដែលស្រដីឲ្យរង្កៀសចិត្តកូនឡើយ គួរប្រាប់ដល់ម្តាយនោះ ៗ ព្រះមហោសថពោធិសត្វ ក្រាបទូលថា បពិត្រព្រះភូមិន្ទនរិន្ទនរនាថ អំពើឯណាដែលគំបាំងពុំប្រាកដ អ្នកប្រាជ្ញទាំងឡាយមិនដែលនិយាយប្រាប់ដល់អ្នកដទៃទេ បើអំពើគំបាំងនោះជាអំពើល្អ ទើបប្រាប់ដល់អ្នកដទៃ ៗ ស្តេចស្តាប់ព្រះពោធិសត្វ

ឆ្លើយដូច្នោះហើយ ទ្រង់មានព្រះទ័យពុំសប្បាយ ពុំមានព្រះរាជ-ឱង្ការទៅទៀតឡើយ ។ អាចារ្យសេនកៈ រមិលមើលទៅព្រះភ័ក្ត្រព្រះរាជា ១ រមិលមើលទៅមុខអាចារ្យសេនកៈ ព្រះមហោសថពោធិសត្វ ទ្រង់យល់ហេតុនោះហើយគិតថាៈ អាចារ្យទាំង ៤ នាក់មុខជាឡើងមកទូលស្តេច គាប់បំបែកឲ្យជាសត្រូវនឹងអញ កាលពីមុនអាចារ្យទាំង ៤ បានទៅសួរអញជាល្បែងលេងទេ ឥឡូវនេះវានាំពាក្យនេះជាប្រទូស្តវិញ ។ លុះឆ្លើយប្រស្នាគ្រប់ទាំងអស់គ្នាហើយ ព្រះអាទិត្យក៏អស្តង្គត ព្រះបរមពោធិសត្វ ក៏ថ្វាយបង្គំព្រះរាជាចុះចេញទៅ ហើយទ្រង់គិតថាៈ អាចារ្យទាំង ៤ ឆ្លើយប្រស្នាថ្វាយព្រះរាជា អ្នកខ្លះថាគួរប្រាប់ដល់មិត្រ, ខ្លះថាគួរប្រាប់ដល់ប្អូន, ខ្លះថាគួរប្រាប់ដល់កូន ខ្លះថាៈគួរប្រាប់ដល់ម្តាយ; អំពើនេះ សមបើបាននិយាយគ្នានឹងព្រះរាជា ជាប្រាកដ បើដូច្នោះ អញនឹងធ្វើឲ្យបានដឹងអំពើអាចារ្យទាំង ៤ នាក់ក្នុងថ្ងៃនេះ ។ អ្នកទាំង ៤ នោះបើចុះមកពីគាល់ព្រះរាជា តែងតែនិយាយគ្នាត្រង់ទ្វារព្រះរាជវាំង ហើយទើបហួសទៅផ្ទះខ្លួនទីទៃ ។ ពោធិសត្វគិតដូច្នោះហើយ ក៏ទ្រង់ប្រើបុរសម្នាក់ ឲ្យយកកំពលមកក្រាលក្រោមកេងធ្លាយ ហើយទ្រង់ចូលទៅនៅត្រង់កន្ទងនោះ ទ្រង់ផ្តាំបុរសនោះថាៈ បើអាចារ្យទាំង៤ចុះហួសទៅ សឹមព្រះស្តង់មកប្រាប់អញ បុរសនោះក៏ថយចេញទៅចាំឃ្លាំមើលតាមបង្គាប់ ។

ចំណែកអាចារ្យសេនកៈ ឃើញព្រះពោធិសត្វ ថ្វាយបង្គំ

ព្រះរាជាចេញមកដូច្នោះ ក៏ក្រាបទូលព្រះរាជាថា: បពិត្រព្រះអង្គ ឥឡូវនេះដូចពាក្យខ្ញុំព្រះអង្គទូលមែនទេ? ព្រះរាជាពុំបានពិចារណាឲ្យវែងឆ្ងាយ ស្រាប់តែភ័យសួរទៅអាចារ្យសេនក:ថា: ហៃអាចារ្យ ឥឡូវនេះតើយើងនឹងគិតធ្វើដូចម្តេច? បពិត្រព្រះអង្គ អំពើនេះយើងកុំឲ្យអ្នកណាដឹង កុំបង្អង់យូរ យើងសម្លាប់មហោសថនេះចេញ ដ្បិតវាជាសត្រូវនឹងព្រះអង្គ ព្រះរាជាឮដូច្នោះ ក៏ចាប់ព្រះខាន់ហុចទៅអាចារ្យសេនក:ប្រាប់ថា: ចូរអាចារ្យឯងយកព្រះខាន់នេះទៅ ហើយចូរប្រើបុរសឯណាមួយដែលទុកចិត្ត ឲ្យកាន់ព្រះខាន់នេះទៅឈររក្សាមាត់ទ្វារ បើមហោសថចេញមកបំរើអញក្នុងវេលាព្រឹកនេះ ចូរកាត់យកក្បាលវាមកថ្វាយអញកុំខាន ។ អាចារ្យទាំង៤ក៏ថ្វាយបង្គំព្រះរាជាទូលថា: សូមព្រះអង្គកុំព្រួយព្រះហឫទ័យ ខ្ញុំព្រះអង្គទាំង៤នឹងសម្លាប់មហោសថមកថ្វាយ; ហើយក៏ថ្វាយបង្គំព្រះរាជាចុះពីព្រះរាជនិវេសន៍ទៅអង្គុយជិតកន្លែងដែលមហោសថចាំពួនស្តាប់ ហើយនិយាយគ្នាថា: យើងសម្លាប់មហោសថឲ្យបានតាមបំណងចិត្តយើង អាចារ្យទាំង៣ធ្វើជានិយាយកោតខ្លាចអាចារ្យសេនក: ថាមានតែលោកម្ចាស់ទេ ទើបគិតការជាទម្ងន់នេះបាន ។ អាចារ្យសេនក:និយាយថា:កាលអ្នកក្រាបទូលព្រះរាជាថា:សេចក្តីកំបាំង គួរសម្តែងប្រាប់កូនប្រាប់ប្អូន, ប្រាប់ម្តាយ, ឥឡូវទីនេះជាទីស្ងាត់ ចូរយើងនិយាយប្រាប់គ្នាឲ្យបានដឹងមើល! អាចារ្យសេនក:ថា:សេចក្តីកំបាំងខ្ញុំនេះ បើមហោសថដឹងហើយនាំពាក្យនេះទៅ

ក្រាបទូលស្តេច មុខជាខ្ញុំនឹងក្ស័យជីវិត ៖ អាចារ្យតាំងពាថា៖ លោកអាចារ្យកុំខ្លាច ទីនេះគ្មានអ្នកណាឮឡើយ ចូរយើងនិយាយប្រាប់ឲ្យទៅមកទាំងអស់គ្នាផង ។ អាចារ្យសនកៈក៏ប្រាប់ថា៖ កាលព្រះបាទកុសរាជជាព្រះវរបិតាព្រះមហាក្សត្រស្តេចយាងទៅប្រពាតឧទ្យាន ខ្ញុំក៏បានហែស្តេចទៅ! ខ្ញុំបានឃើញស្រីផ្កាមាសម្នាក់ មានរូបឆោមលោមពណ៌ល្អខ្ញុំទប់ចិត្តពុំបានក៏នាំស្រីនោះទៅក្នុងព្រៃស្ងាត់ ហើយសេពអសទ្ធម្មដោយអំណាចកាមគុណ ខ្ញុំមានចិត្តលោភហ៊ានសម្លាប់យកគ្រឿងប្រដាប់ដែលព្រះរាជាឲ្យស្រីនោះ, ទុកជាទ្រព្យរបស់ខ្លួន ហេតុនេះ បានជាខ្ញុំមិនប្រាប់ដល់អ្នកដទៃក្រៅពីសម្លាញ់ឡើយ ។ អាចារ្យបុក្កុសៈប្រាប់ថា ការកំបាំងរបស់ខ្ញុំគឺខ្ញុំមានឃ្លង់ដំបៅ ត្រង់ដើមក្លៀមានទឹករងៃហូរពេញសំពត់អស់កាលយូរឥតអ្នកណាមួយដឹងឡើយ មានតែប្អូនខ្ញុំ ១ វាដឹង កាលណាបើព្រឹកព្រហាម វាយកទឹកមកលាងខ្ទុះរបស់វាយកថ្នាំមកបោប រួចយកសំពត់រុំមិនឲ្យមានហ្មងឡើយ ទើបស្លៀកសំពត់ពីក្រៅ ហើយខ្ញុំទៅគាល់ស្តេចជូនជាថ្ងៃនោះ ស្តេចមកគង់លើភ្លៅខ្ញុំ ហើយយកព្រះហស្តស្ទាបអង្អែលទ្រង់សរសើរថា៖ ភ្លៅបុក្កុសៈទន់ស្រួលណាស់ ហើយស្តេចយកព្រះកេសមកផ្ទំលើភ្លៅខ្ញុំទៀត ស្រាប់តែឃ្លង់នោះវាហូរទឹករងៃជ្រាបដល់កុងព្រះកេសព្រះរាជា នៃលោកអាចារ្យ អំពើកំបាំងនេះ បើស្តេចជ្រាបហើយមុខជាសម្លាប់ខ្ញុំមិនខាន ហេតុនេះ បានជាខ្ញុំមិនប្រាប់អ្នកណា ប្រាប់តែប្អូនស្រីខ្ញុំមួយ ។ អាចារ្យកាមិន្ទៈប្រាប់ថា៖ ការកំបាំងរបស់ខ្ញុំគឺ៖ កាល

ណា បើដល់ថ្ងៃឧបោសថជាប់ខែ មានខ្មោចយក្ស១ឈ្មោះនរទេព វាតែង មកចូលផាន់ខ្ញុំ ហើយខ្ញុំស្រែកដូចឆ្កែឆ្កួតខ្លាំងក្រៃ កូនខ្ញុំវាតែងចាប់យក ទៅចងភ្ជាប់នឹងសសរល្វែងខាងក្នុងផ្ទះ ហើយហៅគ្រូមកលេងឲ្យប្រឡឹង នឹងសម្រែកខ្ញុំ មិនឲ្យអ្នកដទៃដឹងឮឡើយ ការណ៍នេះ បើស្ដេចជ្រាប ថាខ្ញុំឆ្កួតដូច្នេះហើយ មុខជាសម្លាប់មិនខាន ហេតុនោះបានជាខ្ញុំថាប្រាប់ កូននោះប្រសើរ ៗ អាចារ្យទេវិន្ទ:ប្រាប់ថា ការកំបាំងខ្ញុំនេះគឺ កាល ណោះព្រះបាទកុសរាជ ជាព្រះវរបិតាព្រះរាជាយើងនេះ ព្រះឥន្ទ្រឲ្យ កែវមណីរ័តន៍មកស្ដេចនោះឲ្យរុងរឿងច្រើនជាមង្គល លុះដល់ស្ដេចទ្រង់ អាពាធជាទុរន់ ខ្ញុំឡើងទៅចាំមើលព្រះជម្ងឺ ខ្ញុំឃើញកែវនោះ ក៏លួច យក បានហើយខ្ញុំយកទៅឲ្យម្ដាយខ្ញុំគាត់រក្សា ខ្ញុំក៏មានសេរីសួស្ដី, ម្ដាយ ខ្ញុំមិនឲ្យអ្នកណាមួយដឹងឡើយ, តែកាលណាខ្ញុំទៅគាល់ស្ដេច ៗ មាន ព្រះបន្ទូលហៅខ្ញុំជាមុន ហើយទ្រង់ព្រះរាជទានមាស ៨ ដម្លឹង ម្ដង, ១៦ ដម្លឹងម្ដង, ៣២ ដម្លឹងម្ដង, ៦៤ ដម្លឹងម្ដង; ខ្ញុំបានដោយសារកែវ មណីរ័តន៍នេះឯង ការណ៍នេះ បើស្ដេចជ្រាបហើយមុខជាខ្ញុំអស់ជីវិតមិន ខាន ៗ ព្រះមហោសថពោធិសត្វអង្គុយក្រោមពេងបាយ ត្រពាក្យ អាចារ្យទាំង ៤ ក៏កត់សំគាល់ទុកក្នុងចិត្តចាំទាំងអស់ ៗ

ចំណែកអាចារ្យទាំង ៤ នាក់និយាយហាក់ដូចជាទម្លាយផ្ទៃរបស់ខ្លួន ហើយប្រាប់គ្នាថា: អ្នកទាំងឡាយកុំប្រហែស ចូរមកអំពីព្រឹកយើងនឹង សម្លាប់មហោសថឲ្យបានដូចបំណង លុះនិយាយគ្នាដូច្នោះហើយ ក៏ដើរ

ទៅផ្ទះខ្លួនរាល់គ្នាទៅ ៗ ឯបុរសពោធិសត្វដែលចាំឃ្លាំមើល ដល់ឃើញអាចារ្យទាំង ៤ ដើរហួសទៅផុតផ្ទះ ក៏ចូលទៅបើកកេងបាយឡើងមើលពោធិសត្វចេញទៅ លុះដល់ផ្ទះក៏ស្រង់ទឹកជម្រះកាយ រួចសោយគោជនាហារដ៏មានឱជារស ហើយទ្រង់គិតថា៖ យប់នេះនាងខុទ្ទកាទេវីជាព្រះអគ្គមហេសីព្រះរាជា មុខជាឲ្យនាំដំណឹងមកដល់អញមិនខាន ក៏ទ្រង់ប្រើបុរសម្នាក់ឲ្យទៅចាំទ្វារ ហើយទ្រង់ផ្តាំថា៖ បើមានបម្រើមកពីនាងខុទ្ទកាទេវី ចូរអ្នកឲ្យចូលមកអញជាប្រញាប់កុំឲ្យយូរ លុះផ្តាំស្រេចក៏ទ្រង់ចូលទៅផ្ទំលើអាសនៈដ៏ប្រសើរទៅ ៗ

តស្មឹំ ខណេ ក្នុងខណៈនោះ ព្រះបាទវិទេហរាជ ស្តេចចូលទៅគង់លើគ្រែក្រឡាព្រះបន្ទំព្រំស្រណុកព្រះហឫទ័យទ្រង់ នឹកឃើញគុណព្រះមហោសថថា៖ មហោសថអ្នកប្រាជ្ញនេះ មកបំរើអញតាំងពីអាយុ ៧ ឆ្នាំមកដល់ឥឡូវនេះ មិនដែលធ្វើអំពើឥតប្រយោជន៍ណាមួយដល់អញឡើយ កាលទេវតាមកសួរប្រស្នាក៏ឆ្លើយជំនួសអញ បើប្រសិនជាអត់អំពីមហោសថទៅហើយ មុខជាជីវិតរបស់អញក៏គ្មានដែរ ស្តេចទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏ទ្រង់ព្រះកន្សែងរៀបរាប់ថា ម្តេចឡើយរាគ្នាអញមកជឿសំដីរបស់អាចារ្យទាំង ៤ ជាអ្នកពាលកំឡៅ និយាយបង្កាច់ថាមហោសថប្រព្រឹត្តក្បត់ ក៏អញពុំពិចារណាឲ្យច្បាស់ប្រាកដ ស្រាប់តែប្រើឲ្យយកព្រះខាន់ទៅសម្លាប់កូនកំសត់តាមចំណង់របស់វា ឱ! មហោសថពុំអារទុក

ហើយ អ្នកមានសំដីពីរោះ មានប្រាជ្ញាឥតអ្នកណាមួយស្មើ អំពើដែលអញធ្វើនេះមិនគួរសោះ ស្ដេចទូញថ្ងូរ ក៏ចេញព្រះសេទោពេញទាំងព្រះកាយ ឥតសប្បាយព្រះទ័យសោះឡើយ ។

វេលានោះ នាងខុជ្ជាទៅដល់ព្រះអគ្គមហេសី នាងយាត្រាទៅព្រះរាជធាមន្ទីរតាមប្រក្រតី នាងយល់ស្ដេចពុំសប្បាយដូចសព្វដង នាងគិតថា: ព្រះស្វាមីរបស់អញ សមបើមានខ្វល់នឹងអ្នកណាមួយហើយ នាងនឹករកទោសរបស់នាងក៏ពុំឃើញ នាងសួរថា: បពិត្រព្រះអង្គ ហេតុអ្វីក៏ព្រះអង្គមានព្រះទ័យពុំសប្បាយ ? ឬមួយក៏ព្រះអង្គមានបើធ្វើឲ្យខុសគន្លងដូចម្ដេច ? ។ ព្រះរាជាស្ដេចមានបន្ទូលតបទៅថា: ភទ្ទេ ម្នាលប្អូនស្រី នាងឥតមានទោសកំហុសអ្វីទេ នាងអើយ អាចារ្យទាំង៤ ឡើងមកប្រាប់បងថា មហោសថ មានចិត្តក្បត់នឹងបង ហើយបងឲ្យគេទៅសម្លាប់ទៅហើយ ហេតុនោះ បានជាបងមិនសប្បាយក្នុងចិត្ត នាងឮដូច្នោះហើយមានព្រះទ័យទង្គឹះផ្អូកផ្អះមានទុក្ខធំហាក់ដូចភ្នំរលំសង្កត់មកលើ ដ្បិតនាងខ្លាចព្រាត់ប្រាសចាកព្រះពោធិសត្វជាប្អូនពៅ ហើយនាងលោមព្រះរាជាឲ្យស្រួលព្រះហឫទ័យធូរលក់ ហើយនាងឲ្យនាំដំណឹងទៅប្រាប់មហោសថថា: ម្នាលប្អូន អាចារ្យទាំង៤មកក្រាបទូលព្រះរាជាថា ឯងមានចិត្តក្បត់នឹងស្ដេច ។ ទ្រង់ខ្វល់បង្គាប់អ្នកទាំង ៤ នោះឲ្យទៅចាំសម្លាប់នៅក្បែរមាត់ទ្វារ បើប្អូនចេញមកគាល់ស្ដេចក្នុងព្រឹកស្អែក គេ

នឹងសម្លាប់មិនខានឡើយ ហេតុនេះ ប្អូនកុំឡើងមកគាល់ ៗ លុះសរសេរសំបុត្ររួចសព្វគ្រប់ហើយ នាងដាក់សំបុត្រនោះក្នុងនំ យកអំបោះរុំគ្រប នឹងការដន៍ថ្នបិទភ្ជាប់ ហើយឲ្យទៅខ្ញុំស្រីដែលបំរើផ្ដាំថា ចូរនាងយកម្ហូបនេះទៅជូនមហោសថប្អូនអញ ៗ នាងស្រីនោះក៏ធ្វើតាមបង្គាប់ ៗ ពាក្យសួរថា ពេលរាត្រីយប់ដូច្នោះ តើធ្វើម្ដេចបានជាស្រីនោះចេញដើរទៅបាន? ឆ្លើយថា ដ្បិតស្ដេចបានប្រទានពរឲ្យនាងទៅអំពីដើម ហេតុនោះ បានជាគ្មានអ្នកណាមួយហ៊ានឃាត់ ៗ ឯព្រះមហោសថក៏ទទួលការដន៍អំពីនាងស្រីនោះ ហើយឲ្យនាងនោះត្រឡប់វិលទៅវិញ រួចព្រះអង្គបើកការដន៍ហែកនំនោះចេញ ឃើញសំបុត្ររបស់នាងឧទុម្ពរាទេវី ទ្រង់ពិចារណាកិច្ចដែលគាប្បីធ្វើ ហើយផ្ទុំទៅ ៗ

ចំណែកអាចារ្យទាំង ៤ លុះព្រឹកព្រហាមកាលណា ក៏កាន់ព្រះខាន់មកឈរចាំត្រង់ខ្លោងទ្វារ ដល់មិនឃើញមហោសថចេញមក ក៏កើតទុក្ខនាំគ្នាទៅកាន់សំណាក់ព្រះរាជា ៗ ព្រះរាជាឃើញហើយទ្រង់សួរថា: ម៉េចមហោសថអ្នកឯងសម្លាប់ហើយឬ? បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនឃើញវាដើរចេញមក ៗ ឯព្រះមហោសថលុះព្រះអាទិត្យរះភ្លឺច្បាស់ក៏ទៅកាន់ព្រះរាជវាំងជាមួយមហាជនជាបរិវារយ៉ាងច្រើន លុះដល់ហើយព្រះអង្គចុះពីលើរទេះមកថ្វាយបង្គំព្រះរាជា ហើយអង្គុយជាមួយអាចារ្យទាំង៤ក្នុងទីនោះ ៗ ព្រះរាជាធ្វើដូចជាមិនដឹងហើយសួរថា: ហៃបាមហោសថ

បាទៅអំពីម្សិល ពេលបឋមយាម លុះថ្ងៃនេះទើបបានមក ចិត្តបាសង្កា ដូចម្តេច? អ្នកណាជាអ្វីទឹងបា ចូរបាសម្តែងប្រាប់មក ព្រះមហោសថ ក្រាបទូលថា: បពិត្រព្រះសម្មតិទេពព្រះអង្គជឿពាក្យអាចារ្យទាំង ៤ ព្រះអង្គបង្គាប់ឲ្យសម្លាប់ខ្ញុំ ហេតុនោះ បានជាខ្ញុំព្រះអង្គមិនមក ។ ព្រះរាជា ឮដូច្នោះក៏ទ្រង់រមិលមើលទៅនាងឧទុម្ពរាទេវីដោយនឹកថា: ច្បាស់ជានាង ឲ្យដំណឹងទៅមហោសថក៏ទ្រង់ខ្ញាល់នឹងនាង ។ ព្រះមហោសថក្រាប ទូលថា: ព្រះអង្គទ្រង់ខ្ញាល់នឹងនាងទេវីធ្វើអ្វី? ការកន្លងទៅហើយក្តី អំពើជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះអង្គក៏ដឹងច្បាស់ទាំងអស់ អំពើកបាំងរបស់ អាចារ្យទាំង៤ តើនរណាប្រាប់ខ្ញុំ គឺខ្ញុំព្រះអង្គដឹងទាំងអស់ ឥតកបាំងនឹង ប្រាជ្ញាខ្ញុំឡើយ ហើយទ្រង់ក៏យករឿងកំបាំងរបស់អាចារ្យទាំង ៤ ដូចន័យ ដែលបានថ្លែងរួចហើយទូលដល់ព្រះរាជា ស្តេចក៏សួរទៅអាចារ្យទាំង ៤ ថា: មែនឬអ្នកទាំងអស់គ្នា ក្រាបទូល ពិតមែនព្រះអង្គ ។ អាចារ្យទាំង ៤ គិតគ្នាថា: ឱ! យើងនឹងសម្លាប់មហោសថ ហេតុអ្វី ក៏ត្រឡប់ជាដូច្នេះវិញ ។ ព្រះមហោសថក្រាបទូលព្រះរាជាថា: បពិត្រព្រះអង្គខ្ញុំព្រះអង្គថា: ការកំបាំងមិនគួរសំដែងប្រាប់អ្នកដទៃ បើប្រាប់អ្នកដទៃមុខជាសេចក្តីវិនាស នឹងមានដល់ខ្លួនឯងមិនលែងឡើយ ព្រះពោធិសត្វ ក៏សំដែងធម៌ទេសនា ដល់ព្រះរាជា ជាច្រើនប្រការ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ក៏មានព្រះហឫទ័យខ្ញាល់នឹងអាចារ្យ ទាំង ៤ ស្តីថា: ពកទាំងនេះជាទោសនឹងកញ ហើយត្រឡប់មកធ្វើ



មហោសថឲ្យដាទោសទំងអញ្ចះទៅវិញ ហើយទ្រង់បង្គាប់ឲ្យចាប់អាចារ្យទាំង ៤ នាក់ចងដៃទៅក្រោយទំងវាយដំយ៉ាងខ្លាំង នាំចេញអំពីនគរទៅដើម្បីសម្លាប់ ព្រះមហោសថពោធិសត្វក្រាបទូលអង្វរថា សូមព្រះអង្គអត់ទោសដល់អាចារ្យទាំង ៤ ៗ ព្រះរាជាឲ្យនាំអាចារ្យទាំង ៤ នោះមកឲ្យធ្វើជាខ្ញុំព្រះពោធិសត្វ ព្រះអង្គមិនទទួល ក៏ថ្វាយឲ្យធ្វើខ្ញុំស្តេចដូចដែលវិញ ៗ ចាប់ដើមតាំងពីថ្ងៃនោះមក អាចារ្យទាំង ៤ ដូច

ជាពស់គេដកចង្កូម ឥតពិសមិនអាចនឹងស្រដីអ្វីដល់តិចតួចឡើយ ព្រះរាជាទ្រង់ស្តាប់លែងជឿតាមអាចារ្យទាំង ៤ តាំងពីពេលនោះ ។

តគោ បដ្ឋាយ ចាប់ដើមអំពីនោះទៅ ព្រះមហោសថអ្នកប្រាជ្ញ ប្រដៅធម៌អាថ៌ដល់ព្រះបាទវិទេហរាជ ។ លុះកាលតមក ពោធិសត្វរំពឹងគិតក្រែងអនាគតកាល មានកើតភ័យទីងសត្រូវអំពីស្តេចដទៃ ក៏ព្រះអង្គឲ្យធ្វើបន្ទាយយ៉ាងធំហើយឲ្យជីកគូរបី „គូរទឹក-គូរផុក-គូរខ្សាច់„ ហើយឲ្យជីកស្រះធំបើកទឹកទំលាយស្ទឹងស្រះជាច្រើន ខ្លាចក្រែងមានភ័យផ្សេងៗទៅអនាគតព្រះអង្គខំព្យាយាមរៀបចំព្រះនគរឲ្យបានចុះចើងរុងរឿងបរិបូណ៌ដោយភោ-គសម្បត្តិគ្រប់ប្រការ ព្រមទាំងការពារមិនឲ្យមានបច្ចាមិត្តណាមួយមកយាយីបៀតបៀនបានឡើយ , ទ្រង់បានចាត់អមាត្យឲ្យទៅធ្វើការរាជការថ្វាយស្តេចដទៃៗគ្រប់ប្រទេស ដើម្បីស៊ើបយកការស្ងាត់កំបាំង ក្រែងមានស្តេចណាមួយមានគំនិតដ៏អាក្រក់លាមក អាងអំណាចរបស់ដ៏លោភលើនគរដទៃៗ ។ ទ្រង់ចិញ្ចឹមសេកសោមបណ្ឌិតមួយ ហើយទ្រង់ចាត់ឲ្យហើរទៅស៊ើបការឯនគរនានា សេកនោះក៏ហើរទៅស៊ើបមើល ស្រាប់តែបានឃើញអាចារ្យកេវដ្ឌព្រាហ្មណ៍ជាអ្នកប្រាជ្ញ សម្រាប់ព្រះរាជាព្រះនាម ចុល្លណី សោយរាជ្យក្នុងនគរបញ្ចាល ។

ឯកស្មឹ សមយេ ក្នុងសម័យមួយព្រះបាទចុល្លណី នឹងអាចារ្យកេវដ្ឌព្រាហ្មណ៍នាំគ្នាទៅគិតការក្នុងព្រៃស្ងាត់ថា នឹងគិតរៀបចំនគរឲ្យបានមាំមួន ហើយលើកកងទ័ពសេនាយោធាឲ្យគគ្រឹកគគ្រេងទៅដណ្តើមយកនគរតូចៗ ក្នុងជម្ពូទ្វីបទាំងមូល ឲ្យបានមកបំណុះចុះចូលរបស់ខ្លួនទាំង

អស់ ដល់បាននគរតូចៗហើយ លើកទ័ពទៅដណ្ដើមយកនគរធំៗទៀត ។ សេកបានដឹងការច្បាស់ដូច្នោះហើយ ក៏ហោរត្រឡប់មកថ្វាយដំណឹងនោះ ដល់ព្រះមហាសថជាចៅហ្វាយរបស់ខ្លួនវិញ ។

ព្រះមហាសថបរមពោធិសត្វបានជ្រាបថា នឹងមានពួកបច្ចាមិត្ត គិតនឹងលើកទ័ពមកដូច្នោះហើយ ក៏រៀបប្រុងប្រៀបពួកពលបរិវារ យោធាបំរុងចាំការពារ នឹងបំរុងគ្រឿងសស្ត្រាវុធយុទ្ធភណ្ឌ ព្រមទាំងស្បៀងអាហារ ឲ្យមានល្មមគ្រប់គ្រាន់នឹងប្រើប្រាស់បានយូរឆ្នាំ ទ្រង់ធ្វើបន្ទាយដាក់កងទ័ពជុំវិញពីរៗជាន់ជាស្រេច ។ លំដាប់នោះ អាចារ្យកេវដ្ដព្រាហ្មណ៍ នឹងព្រះបាទចុល្លណីលើកសេនាយោធាទៅច្បាំងដណ្ដើមយកនគរតូចៗ បាន ១០១ នគរ មកជាបរិវារតាមចិត្តប្រាថ្នា រួចហើយក៏តាំងលើកពលកងនគរជាបរិវារទាំងនោះចេញទៅ ដើម្បីនឹងចាប់ព្រះបាទវិទេហរាជ នឹងព្រះមហាសថពោធិសត្វ ប៉ុន្តែព្រះមហាសថបានដឹងមុន ក៏បានប្រើពួកអាមាត្យឲ្យទៅដេញបង្អើលរត់បាត់ខ្ចាត់ខ្ចាយទៅ ។ លុះកាលខាងក្រោយមក លើកកងទ័ព ១៨ អក្ខោភិនីមកឡោមព័ទ្ធនគរមិថិលា ជុំជិតបិទទាំងស្រូវអង្ករ-ទឹក នឹងស្បៀងអាហារ មិនឲ្យនាំចេញចូលទៀត តែបានដឹងដំណឹងថា ព្រះមហាសថបានរៀបចំនគរនេះឲ្យសម្បូណ៌មិនឲ្យខ្វះខាតវត្ថុណាមួយឡើយ ម្ល៉ោះហើយក៏នាំគ្នាគិតបង្កបំបាំងដោយធម៌វិញ ទើបអាចារ្យកេវដ្ដព្រាហ្មណ៍គេប្រុងសួរប្រស្នាផ្ចាញ់ផ្ចាល់ព្រះមហាសថ ។ វេលានោះ ទ្រង់ក៏លើកពលសេនាចេញទៅតទល់ប្រុងនឹងឆ្លើយប្រស្នា ព្រះអង្គគង់លើសេះ

អស្សតរមានដម្លៃគិតជាមាស ១០ សែនដម្លឹង ព្រះហស្តកាន់កែវមួយមាន ពន្លឺភ្លឺផ្លេកកាត់ថ្ងៃមិនបាន ។

អាចារ្យកេវដ្ឋព្រាហ្មណ៍ បានឃើញហើយក៏សួរភ្លាមថា នែចៅមហោសថ យើងមកកាន់ទីនេះយូរថ្ងៃហើយ, អ្នកឯងក្មេងជាងយើងទេ



ហេតុអ្វីមិនធ្វើបដិសណ្ឋារៈគួរសមនឹងយើង ? ឬមួយអ្នកឯងអាងមានកែវ ដម្លៃបុណ្ណឹង? ព្រះមហោសថសួរទៅវិញថា លោកចង់បានកែវនេះឬអ្វី? ថាហើយក៏បោះកែវទៅនឹងដី អាចារ្យកេវដ្ដធ្វើយបា មានអំបើចៅឯងឲ្យក៏ យកដៃ, ហើយឱនក្បាលមកបំរុងនឹងយកកែវ ឯកែវនោះក៏រមៀលមកជិតជើងព្រះមហោសថៗ ឃើញអាចារ្យកែវដ្ដឱនមកក៏ជាន់កផ្ទប់នឹងដីហើយស្រែកថា យី! លោកអាចារ្យ ហេតុអ្វីបានជាមកកថ្វាយបង្គំអញទៅវិញ?



អញគ្រងផានឯងទេតើកុំធ្វើយ៉ាងហ្នឹង គ្រាន់តែឃើញហេតុអាចារ្យកែវដ្ឋ ប៉ុណ្ណោះ ពួកកងទ័ពស្តេចបុល្លណ៍ក៏បាក់បបខូបខ្ញាចរត់ខ្ចាត់ខ្ចាយរប៉ាត់រប៉ាយអស់ទៅ នៅសល់តែស្តេចបុល្លណ៍នឹងអាចារ្យកែវដ្ឋ ព្រះបរមពោធិសត្វក៏ចាប់ផ្តាមកអាចារ្យកែវដ្ឋបោះពោលទៅក្នុងព្រៃ ទន្ទិចក្បាលបែកឈាមរហាម ក្រោកឡើងរត់បាត់ទៅទៀត. ព្រះបាទបុល្លណ៍ក៏សូមចុះចាញ់សុំរួចតែជីវិត ។



លុះក្រោយមក ព្រះមហោសថ ប្រើអមាត្យឲ្យនាំគ្នាជញ្ជូនយកគ្រឿងសស្ត្រាវុធនឹងសំពត់អាវចំនួន ១ ខែទើបអស់ យកទៅគរទុកក្នុងនគរមិថិលាពេញគ្រប់បន្ទាយ ។

លុះព្រះបាទចុល្លណីនឹងអាចារ្យកេវដ្ដព្រាហ្មណ៍ ទៅដល់នគរហើយ មានប្រាថ្នានឹងយកនាងបញ្ចាលធីតា ជាធីតារបស់ព្រះអង្គ ទៅថ្វាយព្រះបាទវិទេហរាជជាអគ្គមហេសី ដើម្បីរកកលឧបាយចាប់ព្រះបាទវិទេហរាជនឹងមហោសថយកទៅសម្លាប់ គ្រាន់តែបញ្ជូនរាជទូតទៅលួងដួងប្រះអស់រាស្ត្រប្រជាជន ឯព្រះមហោសថបានប្រាប់ហេតុសព្វគ្រប់ហើយ ក៏ថ្វាយបង្គំលាព្រះបាទវិទេហរាជ ហើយនាំយកពល ១០០០ ទៅរៀបចំធ្វើបន្ទាយត្រង់ពាក់កណ្ដាលព្រៃដែន ហើយសុំចូលទៅរៀបចំព្រះពន្លាក្នុងនគរឧត្តរបញ្ចាល ព្រះបាទចុល្លណីក៏បើកឱកាសឲ្យព្រះបរមពោធិសត្វរៀបចំតាមបំណង ព្រះពោធិសត្វបានដាក់អាមាត្យឲ្យយាមល្បាតគ្រប់ទ្វារកំផែងទាំង ៤ មិនឲ្យអ្នកណាមួយនាំសារចូលទៅទូលស្ដេចបាន ហើយនាំពលចូលទៅរុះរើប្រាសាទនាងចលាកទេវី ជាព្រះមាតារបស់ព្រះបាទចុល្លណី ទាល់តែសម្ដេចព្រះជននីថ្វាយមាស ១ សែនដម្លឹងទើបឈប់រុះរើ ហើយនាំគ្នាទៅរុះរើផ្ទះអាចារ្យកេវដ្ដទៀត អាចារ្យកេវដ្ដព្រាហ្មណ៍ក៏យំខ្លាំងណាស់ យកប្រាក់ ៨ កោដិមកសូកអង្វរ ព្រះបរមពោធិសត្វព្រះអង្គក៏ឈប់រុះរើ រួចទ្រង់នាំរេហ៍ពលចូលទៅសូមលា ទៅនៅខាងក្រៅវិញ ព្រោះមានគ្នាច្រើនណាស់ សូមព្រះអង្គអនុញ្ញាតខាងក្រៅវិញ

ចុះ លុះព្រះរាជាយល់ព្រមហើយ ព្រះពោធិសត្វចេញមកនៅបន្ទាយ
រូងក្នុងដី ដែលធ្វើទុករួចជាស្រេច បណ្ដោយ១គាវុតទទឹងកន្លះយោជន៍
មានគន្លឹះ ១៦៤ ឯគន្លឹះទ្វារទាំងនោះគ្រាន់តែដំឡោះគន្លឹះ ១ ក៏
ងងឹតដូចលោកន្តរនរកត្រឡប់ផាន់គន្លឹះ ១ ភ្លើងនេះភ្លឺទាំងអស់ដូច
ស្ថានសួគ៌ លុះរៀបចំស្រេចហើយទ្រង់ឲ្យនាំរាជសារទៅទូលព្រះបាទវិ-
ទេហរាជ ៗ ទ្រង់ជ្រាបហើយក៏យាងចូលទៅក្នុងកន្ទួងនោះនៅរង់ចាំ រួច
ផ្ញើរាជទូតឲ្យទូលព្រះបាទចុល្លណី លុះជ្រាបហើយថ្វាយដំណឹងដល់
នាងតលតាទេវីឲ្យនាំនាងបញ្ចាលទេវីយកទៅចុះ ៗ ឯព្រះបាទចុល្លណី
ត្រេកអរណាស់នឹកស្មានថា: មុខជានឹងបានកាត់កស្ដេចវិទេហរាជ ទីង
ព្រះមហោសថក្នុងពេលនេះមិនខាន ក៏លើកពល១៨អក្ខោភិនីចេញផុត
ពីនគរទៅ ៗ ថ្ងៃពីព្រះមហោសថ ដល់ទ្រង់ជ្រាបថា. ស្ងាត់ក្នុងនគរ
ដូច្នោះហើយ ក៏ចាត់អាមាត្យឲ្យទៅចាប់ព្រះរាជវង្សានុវង្ស៤អង្គគឺ:
នាងនន្ទាទេវីជាអគ្គមហេសីព្រះបាទចុល្លណី១, នាងបញ្ចាលធីតា១,
បញ្ចាលកុមារ១, នាងតលតាទេវីជាមាតារបស់ព្រះបាទចុល្លណី១:
នាំយកទៅថ្វាយព្រះបាទវិទេហរាជៗ ទ្រង់អភិសេកនាងបញ្ចាលធីតាក្នុង
ខណ្ឌជាស្រេច ទើបបញ្ចេញរាជទូតពីរយនាក់ ឲ្យនាំរាជានុវង្សទាំង
៤អង្គទៅឯនគរមិថិលា មានទាំងបរិវារហែហម:ចេញទៅផង ៗ
ចំណែកខាងព្រះបាទចុល្លណីនឹងអាចារ្យកេវដ្ដព្រាហ្មណ៍ ព្រមទាំង
ស្ដេច១០១ជាចំណុះនោះ ប្រឹងតែលើកទ័ពមកជិតឥតដឹងសោះ បេះតែ

ស្រែកហ៊ោសន្ធាប់យកជ័យ លុះមកដល់ជិតព្រះមហេសថ ព្រះអង្គ
មានសេចក្តីអាណិតក៏ប្រាប់ថា: អ្នកកល់គ្នាទៅមើលឯទតរបស់ខ្លួន
សិនទៅ កុំប្រឹងចាំងទទេធ្វើអ្វី ៗ ព្រះបាទបុល្លណ៏ទឹកសង្ស័យ
ទ្រង់ប្រើអាមាត្យឲ្យទៅមើល ក៏ជ្រាបថា: បាត់ព្រះវរមាតាបុត្រាបុត្រី
នឹងអគ្គមហេសីដូច្នោះហើយ ក៏តក់ស្លុតក្នុងព្រះទ័យភ័យញាប់ញ័រ
ស្មើតែសន្លប់បាត់ស្មារតី ព្រះអង្គក៏ឱនកាយថ្វាយបង្គំសុំចុះចាញ់ក្នុង



ពេលនោះ ស្តេចទាំង១០១ ក៏សុំផ្ដើជីវិតលើករាជសម្បត្តិថ្វាយព្រះមហោសថ ប៉ុន្តែព្រះបរមពោធិសត្វមិនទទួលយករាជ្យសម្បត្តិទាំងនោះឡើយ គ្រាន់តែទូន្មានស្តេចចុល្លណីនិងអាចារ្យកេវដ្តព្រាហ្មណ៍ឲ្យប្រព្រឹត្តទសពិធរាជធម៌ និងកាន់សុចរិតធម៌ឲ្យត្រឹមត្រូវប៉ុណ្ណោះ ហើយព្រះអង្គនាំស្តេចទាំងនោះ មើលបន្ទាយដែលមានទគន្ទុះ១៦៤ប្រវែង១គាវុតនិងកន្លះយោជន៍ មានក្បូរក្បាច់រចនាផ្សេងៗ គួរជាទីអស្ចារ្យឥតមានមនុស្សណាមួយធ្វើកើត ព្រះរាជាគាល់ព្រះអង្គ កាលបើឃើញហើយក៏មានបីតិសោមនស្ស ត្រេកអររីករាយព្រឺព្រួចស្ទើតែអណ្តែតកាយរាល់ ៗ ព្រះអង្គ ។ ព្រះបាទចុល្លណីសុំប្រគល់ជីវិតនិងនគរតូចធំឲ្យព្រះពោធិសត្វគ្រប់គ្រងថែរក្សាទាំងអស់ ហើយសុំឲ្យព្រះពោធិសត្វបញ្ជូនស្តេចទាំងនោះទៅនគរវិញ ។

ឯព្រះមហោសថពោធិសត្វទ្រង់ត្រឡប់មកកាន់នគរមិថិលាវិញ ព្រះបាទវិទេហរាជក្រឡេកឃើញទ្រង់ស្ទុះទៅឱបសំណេះសំណាល អំពីការបានរួចជីវិត បានសេចក្ដីសុខសិរីសួស្ដីដោយប្រាជ្ញាបារមីរបស់ព្រះពោធិសត្វ ។ នាងបញ្ចាលទេវី មានព្រះរាជបុត្រា១ មាននាមថាទីឃាវុកុមារ ដល់ព្រះបាទវិទេហរាជជាព្រះវរបិតាទ្រង់ទីវង្គត ព្រះពោធិសត្វអភិសេកឃាវុកុមារឲ្យគ្រងរាជ្យស្នងឡើង ព្រះអង្គក៏នាំក្សត្រទាំង៣

ព្រះអង្គទៅថ្វាយព្រះបុទបុល្លណាវិញ ហើយទ្រង់ទទួលយសស័ក្តិជាធំ លើបណ្ដាពស្ដុទាំងនាម៉ឺនសព្វមុខមន្ត្រីគង់ដែនទាំងអស់ បានប្រកបដោយ សុខសួស្ដីសិរីជ័យមង្គលសុវត្ថិភាពរៀងរៀបដរាបទៅ ។

លុះព្រះសាស្ដាទ្រង់នាំធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតក ថា សិរីឱ្យសេដ្ឋី បានមកជាពុទ្ធបិតា នាងសុមនាទេវី បានមក ជាពុទ្ធមាតា ពួកពលនិកាយមហាជនទាំងអស់បានមកជាពុទ្ធបរិស័ទ ព្រះមហោសថអ្នកប្រាជ្ញ គឺ អង្គតថាគតនឹងឯង ។

រឿងរ៉ាវព្រះមហោសថដែលខ្ញុំបានចម្លងពីសាស្ត្រាច្បាប់បុរាណ ដែលចាស់ដាច់ដាច ព្រមទាំងកែសម្រួលសេចក្ដីនិងអក្សរ ដែលខុស ឲ្យបានត្រឹមត្រូវ សូមសន្មតចប់តែប៉ុណ្ណេះហោង ។

# សៀវភៅដែលមានជាវនៅគេហស្ថាន គីម-គី គឺ:

| | | |
|---|---|---|
| ព្រះថោងនាងនាគ . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះបទ្មគោរប់ | ” | ១០៛០០ |
| រឿងជ័យសុរិវង្ស ទី ១ ដល់ទី ៤ ចប់ | ” | ១០៛០០ |
| រឿងនាងពីរគណ្ដាប់ . | ” | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ | ” | ៨៛០០ |
| គេជាដំឌិន ទី ១ ដល់ទី ៧ ចប់ | ” | ៨៛០០ |
| ទឹកកំផ្កាកំ ទី ១ ទី ២ ចប់ . | ” | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . | ” | ៦៛០០ |
| រឿងធន្ទមឿង ទី ១ ទី ២ ចប់ | ” | ៨៛០០ |
| រឿងធ្មេញជ័យ . . | ” | ១២៛០០ |
| រឿងអាឡាដាំងមនុស្សម្នាក់ទិញចង្កៀងទិព្វ | ” | ១៤៛០០ |
| រឿងព្រះសធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ” | ៩៛០០ |
| រឿងកែវឡុងកែវឡាយ ទី ១ ទី ២ ចប់ | ” | ១១៛០០ |
| ពិម្ពាពិលាប . | ” | ១០៛០០ |
| ទាទាធម្មសំរេគ . | ” | ៨៛០០ |
| អ៊ីវកាំងណាំ . | ” | ៤៛០០ |
| រឿងតាវឯក ទី ១ ទី ២ ទី ៣ ទី ៤ | ” | ៤៛០០ |
| កូនកុសពីរនាក់ . . . | ” | ១០៛០០ |
| រឿងរតនាវង្ស ទី ៦ ទី ៧ ទី ៨ . . | ” | ៥៛០០ |

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គីម-គី គី:

| | | |
|---|---|---|
| សុន្ទរកថា . . . | ១ សៀវភៅថ្លៃ | ៥៛០០ |
| សម្ភាសិក្សាបទជំនួយធម្មវិន័យ | | ១២៛០០ |
| ទេវតាភាសិតនិងពុទ្ធភាសិត | " | ៨៛០០ |
| បកិណ្ណកបវត្តិ . | " | ១២៛០០ |
| វេយ្យាករណ៍បាថ ទី ១ | " | ១៨៛០០ |
| " " ទី ២ | " | ១៧៛០០ |
| វេយ្យាករណ៍ខ្មែរ .. | " | ១៣៛០០ |
| ធម្មសង្គហ: ភាគ ១ ភាគ ២ | " | ១៥៛០០ |
| បញ្ញានិទ្ទេស | " | ២៥៛០០ |
| ប្រស្នាតិហាបដិបត្តិ | " | ១៨៛០០ |
| វិធីប្រែបាលី | , | ២៥៛០០ |
| ប្រស្នាអភិធម្ម | " | ២៥៛០០ |
| ប្រស្នាត្រៃគុណ | " | ២៥៛០០ |
| សាមណេរវិន័យបញ្ហា . | " | ១៨៛០០ |

សៀវភៅកំពុងបោះពុម្ពទៅ

រឿងដំបងក្រញូង-ក្អាក់ក្រែក បក្សីចាំក្រុង រឿងចម្ប៉ាថោងចិញ្ចឹមក្រពើ

រឿងវិបុលសង្គ្រាម　　　　រឿងព្រះបាទអជាតសត្រូវ

រឿងសុវណ្ណកិន្នរ　　　　រឿងនិទានទេវទត្ត

រឿងព្រះសុវណ្ណវង្ស　　　　រឿងខ្យង.សាំង

នឹងសៀវភៅ បាលី ខ្មែរ ដទៃទៀតជាច្រើន

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេក្រង់ ភ្នំពេញ
ជិតរោងកុនព្រហ្មបាយ័នផ្ទាល់

រក្សាសិទ្ធិ

រោងពុម្ពអាស្ស៊ីទិដ
ភ្នំពេញ